K03365
TSL Box 4

ករណី - សួ . សំរិត

- អាយុ ៣៩ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។
. អតីត. កម្មកររោងចក្រ កង់ឡាន តាខ្មៅ ។
- បច្ចុប្បន្ន កម្មករ ក.១

. សេពគប់ ដើរផឹកស៊ី និង ចេញចូល ចុះឡើង ជាមួយឈ្មោះ ឌី.ច៉ាន់
" សេអ៊ីអា ៧១ បច្ច. នៅ ក.១ " ក៏បានទទួលការអប់រំ
នយោបាយ ជាបណ្តើរៗ ពីឈ្មោះនេះ ។ ទីបំផុត ក៏ព្រម ចូល
សេអ៊ីអា តាមការអូសទាញ ។

១.៧៣ - បានចូល សេអ៊ីអា នៅរោងចក្រ កង់ឡាន តាខ្មៅ
អ្នកនាំចូល ឌី.ច៉ាន់
អ្នកទទួលស្គាល់ អ៊ុំ.ស៊ីនឿន " សេអ៊ីអា បច្ច. មិនដឹង -
ប្រាក់ខែ ៧០ ដុល្លារ ។
ភារកិច្ច ឃោសនាប្រឆាំង បដិវត្ត ពង្រីកកម្លាំង សេអ៊ីអា និង
ដើរស៊ើករកបណ្តាញខ្មែរក្រហម - ស៊ើបសកម្មភាពមេ
ទាហាន ដែលលក់អង្ករ ប្រេងឥន្ធនៈ ថ្នាំពេទ្យ និង
អាវុធ ទៅតំបន់ រំដោះ ។

សកម្មភាព . ក្រោយ ១៧.៤.៧៥ :

- បានភ្ជាប់ខ្សែ រយៈ ជាមួយ ពិន.ថុន ហើយធ្វើសកម្មភាពប្រឆាំងបដិវត្ត

ក្នុងក្រុម ប្រាក់.សារី " សេអ៊ីអា កម្មករ ក ១ . បច្ចុ. ចាប់ខ្លួន

- បានឃោសនា បំបែកកម្មករចាស់ ពីអង្គការបដិវត្ត ដូចជា ថា កុំជឿ-អង្គការបដិវត្ត ថ្ងៃក្រោយ វាគ្មានសំបូរសប្បាយ អីទេ វាមុខតែបានតែមួយផ្លែតហ្នឹង កុំជឿកម្មាភិបាល ថា កសាងសង្គមស្មើភាព មើលតែផ្ទល្បូវទៅដឹងហើយ កម្មាភិបាល រស់នៅធ្វើការងារស្រួល ឯកម្មករចាស់ រស់នៅ និង ធ្វើការងារ ដូចសត្វ ។
- បានបលនា កម្មករឱ្យទៀង តវ៉ា ទាមទារពេលសំរាក សិទ្ធិសេរីភាព -ដើរហើរ ។
- បានធ្វើឱ្យខូច គុណភាព កៅស៊ូ អស់ ៥០ គ.ក្រ ។
- បានធ្វើឱ្យខូច ម៉ាស៊ីន បិតកៅស៊ូផ្ទៃ ក្នុងកង់ អស់ ១ ផង ។
- បានធ្វើឱ្យ ម៉ាស៊ីន រអាក់រអួលជាញឹកញាប់ ។